Nº 96

15-12-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

******

ឆ្នាំទី ៥ លេខ ៤៦ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្ដាហ៍

ក

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១_១២_១៩៩៧_ព្រះរាជក្រឹត្យ ជស/រកត/១២៩៧/២៧៣ ស្ដីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ២៦៣៧

៦_១២_១៩៩៧_ព្រះរាជក្រឹត្យ នស/រកត/១២៩៧/៧៩ តែងតាំងលោក ទី ពិសិដ្ឋ ជាឧកញ៉ា ២៦៤៣

១៥_១២_១៩៩៧_ព្រះរាជក្រឹត្យ នស/រកត/១២៩៧/៨០ តែងតាំងឯកឧត្ដម សួន សាលិន ជាទីប្រឹក្សារបស់ឯកឧត្ដមនាយករដ្ឋមន្ត្រីទី១ ២៦៤៤

១៥_១២_១៩៩៧ _ព្រះរាជក្រឹត្យ នស/រកត/១២៩៧/៨១ តែងតាំង ឯកឧត្ដម គិត ធៀង ជាទីប្រឹក្សារបស់ឯកឧត្ដមនាយករដ្ឋមន្ត្រីទី១ ២៦៤៥

II. រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

១៥_១២_១៩៩៧_អនុក្រឹត្យ លេខ ៨១ អនក្រ.បក ស្ដីពីការបង្វែរ ឥណទាន ២៦៤៦

៩_១២_១៩៩៧_អនុក្រឹត្យ លេខ ២៤៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៦៤៨

៩_១២_១៩៩៧_អនុក្រឹត្យ លេខ ២៤៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៦៤៩

៩_១២_១៩៩៧_អនុក្រឹត្យ លេខ ២៤៩ អនក្រ.តត ស្ដីពីការតែងតាំងនាយនគរបាលជាតិ ២៦៥០

១៥_១២_១៩៩៧_អនុក្រឹត្យ លេខ ២៥០ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៦៥១

២-សេចក្ដីសម្រេច

១១_១២_១៩៩៧ _អនុក្រឹត្យ លេខ ៥១ សសរ ស្ដីពីការបង្កើតគណៈកម្មការត្រួតពិនិត្យលើរថយន្តដឹកឈើ ២៦៥២

III .ការងារបណ្ដាក្រសួង

១-ទីស្ដីការគណៈរដ្ឋមន្ត្រី

ប្រកាស

៩_១២_១៩៩៧ _ប្រកាស លេខ ១៦៥ ប្រក. ស្ដីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ ២៦៥៥

១២_១២_១៩៩៧ _ប្រកាស លេខ ១៦៧ ប្រក. ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៦៥៦

១៥_១២_១៩៩៧ _ប្រកាស លេខ ១៦៩ ប្រក. ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៦៥៧

២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

១៥_១២_១៩៩៧ _ប្រកាស លេខ ៣៦៨ ពណ.ពកប.ប្រក ស្ដីពីនីតិវិធីរបស់
នាយកដ្ឋានកម្មសិទ្ធិបញ្ញា ២៦៥៨

៣_ទីស្ដីការរដ្ឋមន្ត្រីក្រសួងព័ត៌មាន

ប្រកាស

១៥_១២_១៩៩៧ _ប្រកាស លេខ ៣១៤/៩៧ ពម.ប្រក. ស្ដីពីការតែងតាំង
មន្ត្រីរាជការ ២៦៦១

១៥_១២_១៩៩៧ _ប្រកាស លេខ ៣១៥/៩៧ ពម.ប្រក. ស្ដីពីការតែងតាំង
មន្ត្រីរាជការ ២៦៦២

៤_នីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

១៥_១២_១៩៩៧ _ប្រកាស លេខ ៨៦២ អយក.ប្រក. ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន «ឈើទាល» ស្ថិតក្នុងឃុំរកាក្រៅ ស្រុកដូនកែវ ខេត្តតាកែវ ២៦៦៣

១៥_១២_១៩៩៧ _ប្រកាស លេខ ៨៦៤ អយក.ប្រក. ស្តីពីការប្តូរឈ្មោះ អនុវិទ្យាល័យ «ចាន់ថ្នាល» ទៅជាអនុវិទ្យាល័យ ប៊ុន រ៉ានី_ហ៊ុន សែន «ចាន់ថ្នាល» ស្ថិតក្នុងឃុំក្រាំងចេក ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ២៦៦៥

១៥_១២_១៩៩៧_ប្រកាស លេខ ៨៦៥ អយក.ប្រក. ស្តីពីការប្តូរឈ្មោះ វិទ្យាល័យ កោះអណ្តែត ទៅជាវិទ្យាល័យ ហ៊ុន សែន «កោះអណ្តែត» ស្ថិតក្នុង ស្រុកកោះអណ្តែត ខេត្តតាកែវ ២៦៦៦

៥_នីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

១៥_១២_១៩៩៧_ប្រកាស លេខ ២០៩ បទ. ស្តីពីថ្ងៃសន្និបាតទូរស័ព្ទអន្តរជាតិ និងថ្ងៃសេវាស្លាបនា_ផ្ទេរប្រព័ន្ធទូរគមនាគមន៍ក្នុងក្រុង ២៦៦៨

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ ជស/រកត/១២/៩៧/២៧៣

ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

យើង

ព្រះបាទសម្តេចព្រះនរោត្តមសីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស ៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីច្បាប់សហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត /១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ និងពីរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ស្របតាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

ជំពូកទី ១

បទបញ្ញត្តិទូទៅ

មាត្រា១._ មន្ត្រីរាជការស៊ីវិលទាំងអស់ត្រូវបានរៀបចំជាក្របខ័ណ្ឌ ដែលត្រូវបែងចែកជា ឋានន្តរស័ក្តិ ។ ក្របខ័ណ្ឌត្រូវចាត់ថ្នាក់ទៅតាមប្រភេទ ។

ជំពូកទី ២

អំពីប្រភេទ

មាត្រា២._ ក្របខ័ណ្ឌ មន្ត្រីរាជការស៊ីវិលទាំងអស់ ត្រូវបែងចែកជា ៤ប្រភេទ **ក.ខ.គ** និង **ឃ.** ដែលកំណត់ឡើងដោយយោងទៅតាមល័ក្ខខ័ណ្ឌ អប្បបរមា នៃការបណ្តុះបណ្តាលសំរាប់បញ្ចូលក្នុងក្របខ័ណ្ឌ និងកំរិតឋានានុក្រមនៃតំណែងរបស់ក្របខ័ណ្ឌ ។ ក្របខ័ណ្ឌនីមួយៗ ចាំបាច់ត្រូវចាត់បញ្ចូលទៅក្នុងប្រភេទណាមួយនៃទាំង៤ តាមលក្ខន្តិកៈដោយឡែករបស់ខ្លួន ។

មាត្រា៣._ មន្ត្រីរាជការប្រភេទ **ក** មានមុខងារក្នុងតំណែង ដឹកនាំ អធិការកិច្ច សិក្សា និងផ្តល់យោបល់ និងមុខងារក្នុងរាល់តំណែងទទួលខុសត្រូវ ។ កំរិតអប្បបរមានៃការបណ្តុះបណ្តាល ដើម្បីអាចបញ្ចូលក្របខ័ណ្ឌក្នុងប្រភេទ **ក** គឺសញ្ញាបត្រមធ្យមសិក្សាកំរិត២ បូក៤ឆ្នាំ នៃការសិក្សា ដោយមានសញ្ញាបត្រ ។ លក្ខន្តិកៈដោយឡែកខ្លះអាចប្រសិនបើចាំបាច់ តម្រូវនូវកំរិតអប្បបរមានៃការបណ្តុះបណ្តាលស្មើ ឬលើសសញ្ញាបត្រមធ្យមសិក្សាកំរិត២ បូក៦ឆ្នាំ នៃការសិក្សាដោយមានសញ្ញាបត្រ ។ ក្នុងករណីនេះ ត្រូវមានផ្តល់នូវការបន្ថែមសន្ទស្សន៍បៀវត្ស ។

មាត្រា៤.– ប្រភេទ ខ មានមុខងារក្នុងការរៀបចំការងារ សំរាប់អ្នកទទួលខុសត្រូវសំរេច និងដាក់ អោយអនុវត្ត ។ កំរិតអប្បបរមា ដើម្បីបញ្ចូលក្របខ័ណ្ឌទៅក្នុងប្រភេទ ខ គឺសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ បូក២ឆ្នាំ នៃការសិក្សាដោយមានសញ្ញាបត្រ ។

មាត្រា៥.– ប្រភេទ គ មានមុខងារក្នុង លេខាធិការដ្ឋាន និង មុខងារប្រតិបត្តិដែលតម្រូវអោយមានចំណេះបច្ចេកទេស ឬចំណេះធ្វើការងារ ។ កំរិតអប្បបរមា ដើម្បីបញ្ចូលក្របខ័ណ្ឌទៅក្នុងប្រភេទ គ គឺសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ ។

មាត្រា៦.– ប្រភេទ ឃ មានមុខងារក្នុងការប្រតិបត្តិ ។ ការបញ្ចូលក្របខ័ណ្ឌទៅក្នុងប្រភេទនេះពុំតម្រូវអោយមានលក្ខខ័ណ្ឌអំពីសញ្ញាប័ត្រឡើយ ។

មាត្រា៧.– កំរិតអប្បបរមានៃការបណ្តុះបណ្តាលដែលបានកំណត់ក្នុងមាត្រា ៣.៤.និង ៥. នៃព្រះរាជក្រឹត្យនេះ ត្រូវអនុវត្តចំពោះនិស្សិតទាំងឡាយណា ដែលត្រូវបានជ្រើសរើសអោយចូលមុខងារសាធារណៈ តាមការប្រឡងប្រជែង ចាប់ពីថ្ងៃផ្សព្វផ្សាយព្រះរាជក្រឹត្យនេះ ។

មាត្រា៨.– មន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញភារកិច្ចក្នុងមុខតំណែង តាមការតែងតាំងដែលមានរួចហើយ ត្រូវផ្ទេរបញ្ចូលក្នុងក្របខ័ណ្ឌថ្មី ។ គណៈកម្មការអន្តរក្រសួងមួយនឹងត្រូវបានតែងតាំងដោយអនុក្រឹត្យ ដើម្បីលើកគោលការណ៍សំរាប់ការចាត់ថ្នាក់ថ្មីជូនរាជរដ្ឋាភិបាលពិនិត្យនិងសំរេច ។

ជំពូកទី ៣

អំពីក្របខ័ណ្ឌ

មាត្រា៩.– ក្របខ័ណ្ឌនីមួយៗ នៃមន្ត្រីរាជការ គឺជាការប្រមូលផ្តុំភ្នាក់ងារ ដែលមានគុណសម្បត្តិ ឬការបណ្តុះបណ្តាលដូចគ្នា ហើយដែលមានឧបនិស្ស័យកាន់តំណែងដូចគ្នា ឬប្រភេទមុខតំណែងដូចគ្នា ក្នុងអាជីពរបស់ខ្លួននៅក្នុងក្រសួងណាមួយ ។

មាត្រា១០.– ក្របខ័ណ្ឌនីមួយៗ ត្រូវស្ថិតនៅក្រោមលក្ខន្តិកៈដោយឡែកមួយដែលរៀបចំដោយក្រសួងសាមី និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។ លក្ខន្តិកៈដោយឡែកត្រូវកំណត់ឡើងដោយព្រះរាជក្រឹត្យ និងដោយមានការយល់ព្រមពីគណៈកម្មាធិការ

ប្រតិបត្តិនៃគណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង ដើម្បីកែទំរង់រដ្ឋបាល និងពីក្រុមប្រឹក្សាអ្នកច្បាប់ ។

មាត្រា១១.– លក្ខន្តិកៈដោយឡែកបង្កើតក្របខ័ណ្ឌនីមួយៗ និង រៀបចំអាជីព ត្រូវស្របទៅតាមបទបញ្ញត្តិសហលក្ខន្តិកៈ នៃមន្ត្រីរាជការស៊ីវិល និង តាមអត្ថបទថ្មីនេះ ។ លក្ខន្តិកៈដោយឡែក ត្រូវមានជាចាំបាច់នូវបទបញ្ញត្តិដូចតទៅ :

ក– ការភ្ជាប់ក្របខ័ណ្ឌក្នុងក្រសួងមួយ

ខ– ការចាត់ថ្នាក់ក្របខ័ណ្ឌទៅក្នុងប្រភេទមួយ

គ– ការកំណត់បេសកកម្មទូទៅរបស់ក្របខ័ណ្ឌ

ឃ– ការកំណត់មុខតំណែង ដែលភ្នាក់ងារក្របខ័ណ្ឌត្រូវបំពេញ

ង– ការកំណត់លក្ខណៈសម្បត្តិអប្បបរមា ដើម្បីបញ្ចូលក្នុងក្របខ័ណ្ឌ និងបែបបទនៃការប្រឡងប្រជែងផ្ទៃក្នុងនិងការប្រឡងប្រជែងចូលក្របខ័ណ្ឌរាជការ ដោយនិស្សិតសុទ្ធសាធ

ច– របបកម្មសិក្សាសាកល្បង

ឆ– ការកំណត់ឋានានុក្រមក្របខ័ណ្ឌ (បែងចែកក្របខ័ណ្ឌជាឋានន្តរស័ក្តិ និង កំណត់មុខតំណែងសំរាប់ឋានន្តរស័ក្តិនីមួយៗ)

ជ– វិធានសំរាប់តម្លើងថ្នាក់ និង តម្លើងឋានន្តរស័ក្តិ ។

មាត្រា១២.– អនុក្រឹត្យមួយ នឹងកំណត់ខ្លឹមសារគំរូនៃលក្ខន្តិកៈដោយឡែក និងវិធីអនុវត្ត ដើម្បីបង្កើតក្របខ័ណ្ឌ ។

ជំពូកទី ៤

អំពីឋានន្តរស័ក្តិ

មាត្រា១៣.– ឋានន្តរស័ក្តិ គឺជាលំដាប់ឋានានុក្រមនៃក្របខ័ណ្ឌ ។ ក្របខ័ណ្ឌនីមួយៗចាំបាច់ ត្រូវបែងចែកជា ៣ ឋានន្តរស័ក្តិ ឋានានុក្រម ។ ឋានន្តរស័ក្តិនីមួយៗ ឆ្លើយតបទៅនឹងមុខតំណែង ឬ សារព័ន្ធមុខតំណែង ដែលមានការទទួលខុសត្រូវកាន់តែខ្ពស់ ។

មាត្រា១៤.– និស្សិតដែលមិនមែនជាមន្ត្រីរាជការ ហើយដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងអោយចូលក្នុងមុខងារសាធារណៈ ចាំបាច់ត្រូវតាំងស៊ប់ក្នុងឋានន្តរស័ក្តិដំបូងនៃក្របខ័ណ្ឌ ។

មាត្រា១៥._ជាធម្មតា ភ្នាក់ងារទាំងឡាយអាចមានឱបនិស្ស័យ សំរាប់ដំណើរការអាជីពរហូតក្នុងវិជ្ជាជីវៈរបស់ខ្លួនក្នុងឋានន្តរស័ក្តិដំបូង ដោយមានការតែម្លើងថ្នាក់ជាទៀងទាត់ ទៅតាមបទបញ្ញត្តិនៃសហលក្ខន្តិកៈ និង លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌរបស់ខ្លួន ។

មាត្រា១៦._ការតំឡើងឋានន្តរស័ក្តិ ក្នុងឋានន្តរស័ក្តិទី២ ទី៣ គឺសំរាប់ភ្នាក់ងារណាដែលមានគុណសម្បត្តិជាងគេ ។ ការតម្លើងឋានន្តរស័ក្តិនេះផ្អែកទៅលើភាពទំនេរនៃតំណែង ហើយប្រព្រឹត្តទៅតាមការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬតាមការទទួលបាននូវវិញ្ញាបនបត្រសិក្សារយៈពេលវែង នៅសាលាភូមិន្ទរដ្ឋបាល ឬសាលាអនុវត្តដែលទទួលស្គាល់ដោយលក្ខន្តិកៈដោយឡែក ឬតាមការប្រឡងប្រជែង ។ អាចត្រូវបានតម្លើងឋានន្តរស័ក្តិទី២ នៃក្របខ័ណ្ឌមួយ ចំពោះភ្នាក់ងារទាំងឡាយណាដែលបានឡើងដល់ថ្នាក់ទី៤ នៃឋានន្តរស័ក្តិដំបូងរួចហើយ ។ អាចត្រូវបានតម្លើងទៅឋានន្តរស័ក្តិទី៣ នៃក្របខ័ណ្ឌមួយ ចំពោះភ្នាក់ងារទាំងឡាយណាដែលបានឡើងដល់ថ្នាក់ទី៤ នៃឋានន្តរស័ក្តិ ទី ២ រួចហើយ ។ ការឡើងឋានន្តរស័ក្តិ ទៅឋានន្តរស័ក្តិខ្ពស់ជាងមួយទៀត ផ្តល់ឱបនិស្ស័យដល់សាមីជន ដើម្បីទទួលមុខតំណែងស្របទៅតាម ឋានន្តរស័ក្តិថ្មី ដូចដែលបានកំណត់ក្នុងលក្ខន្តិកៈដោយ ឡែក ។

មាត្រា១៧._បែបបទនៃការដាក់ចំនួនភ្នាក់ងារបច្ចុប្បន្នបញ្ចូលក្នុងឋានន្តរស័ក្តិថ្មីនៃក្របខ័ណ្ឌ និងអន្តរប្បញ្ញត្តិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៥

អំពីថ្នាក់

មាត្រា១៨._ឋានន្តរស័ក្តិនីមួយៗ ត្រូវបានបែងចែកជាថ្នាក់ ដែលមានសន្ទស្សន៍កំណត់ អំពីកំរិតលាភការ ។

មាត្រា១៩._ឋានន្តរស័ក្តិ ទី១ ត្រូវបានចែកចេញជា ១៤ ថ្នាក់ ។ ឋានន្តរស័ក្តិ ទី២ ចែកចេញជា ១០ ថ្នាក់ ។ ឋានន្តរស័ក្តិ ទី៣ ចែកចេញជា ៦ ថ្នាក់ ។

មាត្រា២០._ជាធម្មតា មន្ត្រីរាជការទាំងអស់ ត្រូវបានតម្លើងថ្នាក់ក្នុង២ឆ្នាំម្តង វៀរលែងក្នុងករណីដែលត្រូវបានផ្តល់អត្ថប្រយោជន៍ ស្តីពីអតីតភាព ដែលជាលទ្ធផលចេញមកពីស្នាដៃពិសេស ឬបើជាការចាំបាច់ពីភាពលំបាកពីកំរិតនៃការទទួលខុសត្រូវ ឬពី

លក្ខណៈស្ថិតក្នុងតំបន់ដាច់ស្រយាលនៃមុខតំណែងខ្លះ ។ លក្ខន្តិកៈដោយឡែកត្រូវកំណត់ព្រំដែនជាក់លាក់នៃមុខតំណែង ដែលអាចផ្តល់អត្ថប្រយោជន៍លើអតីតភាពថ្នាក់ ។

ជំពូកទី ៦

អវសានប្បញ្ញត្តិ

មាត្រា២១.– នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា២២.– ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

ព្រះរាជក្រឹត្យ នស/រកត ១២៩៧/៧៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ទី ពិសិដ្ឋ

ជា

ឧត្តមញ៉ា

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

ព្រះរាជក្រឹត្យ នស/រកត ១២៩៧/៨០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស

អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញសំណើរបស់នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា១ .- តែងតាំងឯកឧត្តម **សួន សាឈិន** ជាទីប្រឹក្សារបស់ ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ ទទួលបន្ទុកការងារកិច្ចការបរទេស មានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា២ .- នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៣ .– ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

***

ព្រះរាជក្រឹត្យ នស/រកត ១២៩៧/៨១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស

អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញសំណើរបស់នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាល កម្ពុជា ចុះថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា១.– តែងតាំងឯកឧត្តម គិត ឆៀង ជាទីប្រឹក្សារបស់ ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ ទទួលបន្ទុកការងារកិច្ចការពាណិជ្ជកម្ម មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា២.‒នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៣.‒ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ១៩៩៧

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

II- រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

អនុក្រឹត្យ លេខ ៨១ អនក្រ.បក

ស្តីពីការផ្ទេរឥណទាន

===

រាជរដ្ឋាភិបាល

‒បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

‒បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

‒បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

‒បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

‒បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

‒បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦

ប

- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស/៩៣ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៧ ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៧
- បានឃើញប្រកាសលេខ ០១ ប្រ.សហវ ចុះថ្ងៃទី០៧ ខែ មករា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីចំណាត់ថ្នាក់ ចំណូល និង ចំណាយថវិកាតាមប្រភេទជំពូក ប្រការ កថាខណ្ឌ វាក្យខណ្ឌ នៃច្បាប់ ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤ និងប្រកាសស្តីពីការកែប្រែ និងបំពេញបន្ថែមជាបន្តបន្ទាប់មាន : លេខ ០២២ ប្រ.សហវ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៤ , លេខ ០០៣ ប្រ.សហវ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ , លេខ ៣២៣ ប្រក.សហវ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥ , លេខ ៣៣៦ ប្រក.សហវ.ថ ចុះថ្ងៃទី១២ ខែ តុលា ឆ្នាំ ១៩៩៥, លេខ ០៧១ ប្រក.សហវ.ថ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៦ និង លេខ ៨០១ ប្រ.សហវ.ថ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៦
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១.– ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទាន ពីជំពូក៤១ (ចំណាយឥតគ្រោងទុក) នៃថវិការដ្ឋ ចំនួន ២០០លានរៀល (ពីររយលានរៀលគត់) មកជំពូក១០ (បៀវត្សនិង ប្រាក់បំណាច់) ក្នុងវង់ថវិការបស់ក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ។

មាត្រា២.– ឥណទានក្នុងមាត្រា១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់កិច្ចប្រតិបត្តិការសឹក ជាបន្ទាន់ នាវដូវវស្សារបស់កងយោធពលខេមរភូមិន្ទ ។

មាត្រា៣.– សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

***

អនុក្រឹត្យ លេខ ២៤៧ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការរាជរដ្ឋាភិបាលកម្ពុជា

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

– ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

មាត្រា១._ត្រូវបានតែងតាំងជាជំនួយការឯកឧត្តមនាយករដ្ឋមន្ត្រីទី១

១_លោក **សោម សេរីឧត្តម** ជាជំនួយការផ្នែកសាងសង់

២_លោក **ម៉ែង ភាស៊ី** ជាជំនួយការទំនាក់ទំនងសាធារណៈ

៣_លោក **ម៉ម មុន្នី** ជាជំនួយការផ្នែករដ្ឋបាល

៤_លោក **ស៊ុម មុនី** ជាជំនួយការផ្សព្វផ្សាយ ដោយមានឋានៈស្មើនឹងប្រធាននាយកដ្ឋាន

មាត្រា២._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

អនុក្រឹត្យ លេខ ២៤៨ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការរាជរដ្ឋាភិបាលកម្ពុជា

* * *

រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

_បានៈឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

មាត្រា១.- ត្រូវតែងតាំង លោក អ៊ុត តាន ជាជំនួយការផ្ទាល់របស់ ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ ដោយមានឋានៈស្មើនឹង **ប្រធាននាយកដ្ឋាន** ។

មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត ហ៊ុន សែន

***

អនុក្រឹត្យ លេខ ២៤៩ អនក្រ.តត

ស្តីពីការតែងតាំងនាយនគរបាលជាតិ

—

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា១.– ត្រូវបានតែងតាំងលោក **នុត ជិនឡៀន** ជាទីប្រឹក្សារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទទួលបន្ទុកកិច្ចការនគរបាល ។

មាត្រា២.– ត្រូវបានផ្តល់ក្របខ័ណ្ឌនគរបាលជាតិ ០១កន្លែង (មួយ)សំរាប់លោក **នុត ជិនឡៀន**

មាត្រា៣.– សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង និង ស្ថាប័នពាក់ព័ន្ធ និង លោក **នុត ជិនឡៀន** ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត ហ៊ុន សែន

* * *

អនុក្រឹត្យ លេខ ២៥០ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

—

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-តាមសំណើរបស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

សំរេច

មាត្រា១.-ត្រូវបានតែងតាំងលោក **ម៉ាទ៊ាន ស៊ុទិលិយ** ជាទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា២.-ត្រូវបានផ្តល់ក្របខ័ណ្ឌរដ្ឋបាលស៊ីវិល ០១កន្លែង (មួយ) សំរាប់លោក **ម៉ាទ៊ាន ស៊ុទិលិយ** ។

មាត្រា៣.-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួង និង ស្ថាប័នពាក់ព័ន្ធ និង លោក **ម៉ាទ៊ាន ស៊ុទិលិយ** ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

២-សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៧

សេចក្តីសំរេច លេខ ៥១ សសរ

ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យឈើរថយន្តដឹកឈើ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

–បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

–បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

–យោងការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី១២ ខែ វិច្ឆិកា ឆ្នាំ១៩៩៧

សំរេច

ប្រការ១ : ត្រូវបានបង្កើតគណៈកម្មការត្រួតពិនិត្យលើរថយន្តដឹកឈើ ដែលមានសមាសភាពដូចតទៅ ÷

១–ឯកឧត្តម **គ្រាំ អ៊ីចតិក** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ប្រធាន

២–ឯកឧត្តម តំណាងអគ្គនាយកដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ អនុប្រធាន

៣–ឯកឧត្តម **ខាវ ម៉េងឈាង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៤–ឯកឧត្តម **តាន់ សុផាន់** អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ សមាជិក

៥–ឯកឧត្តម **គីម សាន** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

៦–លោក **សុខ សាម៉ន** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី លេខាធិការ

ប្រការ២ : គណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចតទៅ ÷

១–ធ្វើបទបញ្ញា ស្តីពីការដឹកជញ្ជូនឈើគ្រប់ប្រភេទតាមផ្លូវសាធារណៈ ដោយកំណត់ប្រភេទមធ្យោបាយដឹកជញ្ជូនទម្ងន់ផ្ទុក និងបរិមាណឈើដើម្បីការពារការខូចខាតផ្លូវ និងស្ពាន និងកំណត់សមត្ថកិច្ចច្បាស់លាស់ ក្នុងការអនុញ្ញាតអោយដឹកជញ្ជូនឈើក្នុងប្រទេស ។

២_ធ្វើការផាកពិន័យ ឃាត់ទុកនិងរឹបអូសនូវមធ្យោបាយដឹកជញ្ជូនឈើតាមផ្លូវសាធារណៈ ដែលគ្មានលិខិតអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ។

៣_កសាងសំណុំរឿងបញ្ជូនទៅតុលាការ ចំពោះជនល្មើសដែលបានប្រព្រឹត្តលើបទល្មើសព្រៃឈើ និងដឹកជញ្ជូនឈើដោយគ្មានច្បាប់អនុញ្ញាតពីស្ថាប័ន មានសមត្ថកិច្ច ។

៤_បូកសរុបរាយការណ៍ និងលើកវិធានការអនុវត្តតាមដំណាក់កាលនីមួយៗ ជូននាយករដ្ឋមន្ត្រីទាំងពីរ ។

ប្រការ៣._អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវសហការយ៉ាងជិតស្និទ្ធ ព្រមទាំងផ្តល់មន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធជាតិ ចូលរួមអនុវត្តផ្ទាល់ជាមួយគណៈកម្មការត្រួតពិនិត្យរថយន្តដឹកឈើនេះ ។

ប្រការ៤._សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ៥._គណៈកម្មការនេះ មានសិទ្ធិបង្កើតក្រុមជំនួយការសំរាប់ជួយការងារ ។

_គណៈកម្មការនេះ មានទីស្នាក់ការនៅទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដោយប្រើប្រាស់ថវិកា និងត្រារបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ។

ប្រការ៦._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ដែលមានចែងឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត **ហ៊ុន សែន**

II-ការងារបណ្ដាក្រសួង

១_ទីស្ដីការគណៈរដ្ឋមន្ត្រី

ប្រកាស

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៦៥ ប្រក

ស្ដីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេច ព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២៦ ខែ តុលា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

ប្រការ១ : ត្រូវបានផ្ទេរលោក **គួច គី** អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច ជាអនុប្រធាននាយកដ្ឋានពាណិជ្ជកម្ម ធនាគារ និង ហិរញ្ញវត្ថុនៃទីស្ដីការគណៈរដ្ឋមន្ត្រី

ប្រការ២ : ប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច នាយកដ្ឋានពាណិជ្ជកម្ម ធនាគារ និងហិរញ្ញវត្ថុ ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

សុខ អាន ឈាន ឌី តាន់

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៦៧ ប្រក

ស្ដីពីការតែងតាំងមន្ត្រីរាជការ

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេច ព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២៦ ខែ តុលា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

ប្រការ១ : តែងតាំងលោក **ទ៊ា ឈួដា** ជាប្រធានការិយាល័យ ទទួលបន្ទុក ផ្នែករក្សាប្រមាញ់ និងបរិស្ថាន នៃនាយកដ្ឋានកសិកម្ម នៃទីស្ដីការគណៈរដ្ឋមន្ត្រី ។

ប្រការ២ : ប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច នាយកដ្ឋានកសិកម្ម ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្ត សេចក្តីប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

សុខ អាន ឈាន់ តាន់

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៦៩ ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច ព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២៦ ខែ តុលា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពរការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ១ : តែងតាំងមន្ត្រីរាជការដូចមានឈ្មោះខាងក្រោម ÷

១_លោក ងួ ម៉ុនហៀង ជាប្រធានការិយាល័យ ទទួលបន្ទុកការងារទន្លេមេគង្គ និងអភិវឌ្ឍន៍ជនបទ នៃនាយកដ្ឋានកសិកម្ម ទីស្តីការគណៈរដ្ឋមន្ត្រី ។

២_លោក ឡុង សុខា ជាប្រធានការិយាល័យ ទទួលបន្ទុកការងារក្សេត្រសាស្ត្រ និងគោលនយោបាយកសិកម្ម នៃនាយកដ្ឋានកសិកម្ម ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ២ : ប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច នាយកដ្ឋានកសិកម្ម ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

សុខ អាន **ឈាន់ តាន់**

* * *

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣៦៨ ពណ.ពកប.ប្រក

ស្តីពីនីតិវិធី របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច ព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម

-ពិនិត្យលើសំណូមពរចាំបាច់នៃការងាររបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា

សំរេច

ប្រការ១ : ប្រគល់សិទ្ធិអោយនាយកដ្ឋានកម្មសិទ្ធិបញ្ញា អនុវត្តនូវតួនាទីភារកិច្ច ដែលរដ្ឋបានប្រគល់ ដើម្បីធ្វើការចុះបញ្ជី និង ផ្តល់វិញ្ញាបនប័ត្រពាណិជសញ្ញា និង សេវាសញ្ញាជូនដល់អតិថិជនក្នុង និង ក្រៅប្រទេស និងដោះស្រាយរាល់បញ្ហាដែលកើតឡើងពីការចុះបញ្ជី ។

ប្រការ២ : នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវរួមសហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ការពារពាណិជសញ្ញា និងសេវាសញ្ញាអោយកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីធានាការទុកចិត្តពីអតិថិជន ក្នុងនិងក្រៅប្រទេស ដែលបានចុះបញ្ជីរួចហើយ ។

ប្រការ៣ : ថេរវេលានៃការការពារពាណិជសញ្ញា ត្រូវបានកំណត់រយៈពេល១០ឆ្នាំ និងអាចបន្តចុះបញ្ជីជាថ្មីទៀត ក្នុង១០ឆ្នាំម្តង ។

ម្ចាស់ពាណិជសញ្ញា ឬសេវាសញ្ញា ឬតំណាងដែលបានទទួលសិទ្ធិ ត្រូវរាយការណ៍មកនាយកដ្ឋានកម្មសិទ្ធិបញ្ញា អំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់នូវពាណិជសញ្ញា ឬ សេវាសញ្ញា នៅរៀងរាល់ ៥ឆ្នាំម្តង ។ ការខកខានមិនបានរាយការណ៍ពាណិជសញ្ញា ឬសេវាសញ្ញានោះនឹងត្រូវលុបចេញពីបញ្ជី ។

ប្រការ៤ : ចំពោះអតិថិជនក្នុង និងក្រៅប្រទេស ដែលមានបំណងចុះបញ្ជីពាណិជសញ្ញា ឬសេវាសញ្ញានៅក្នុងព្រះរាជាណាចក្រកម្ពុជា (នាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម) ត្រូវបំពេញសំណុំបែបបទ ព្រមទាំងបង់អាករ និងកំរៃដូចខាងក្រោម :

-ពាក្យសុំចុះបញ្ជី (Application for Registration) ០១ ច្បាប់

- លិខិតប្រគល់សិទ្ធិ (Power of Attorney) ដែលចុះហត្ថលេខាបញ្ជាក់ដោយ មេធាវី ឬ សារការី (Notary public) ០១ច្បាប់
- គំរូពាណិជសញ្ញា ចំនួន ១៥ (15 models of mark)
- ប្រាក់អាករក្នុងការចុះបញ្ជី ៥០ ដុល្លាអាមេរិក
- កំរៃក្នុងការចុះផ្សាយក្នុងព្រឹត្តិប័ត្រ ៥០ ដុល្លាអាមេរិក
- កំរៃស្រាវជ្រាវពាណិជសញ្ញា (Search report) ៥ ដុល្លាអាមេរិក (ប្រសិនបើមានសំណូមពរពីអតិថិជន)

ប្រការ៥ : ការផ្តល់នូវលិខិតទទួលស្គាល់ និង វិញ្ញាបនប័ត្រជាផ្លូវការក្នុងការចុះបញ្ជីពាណិជសញ្ញា ឬសេវាសញ្ញាជូនដល់អតិថិជនក្នុង និងក្រៅប្រទេស គឺធ្វើឡើងក្រោយពេលដែលបានពិនិត្យលើសំណុំលិខិត សុំចុះបញ្ជី ដែលបានចាត់ទុកថាមានលក្ខណៈត្រឹមត្រូវនិងស្របច្បាប់ ។

ប្រការ៦ : ចំពោះពាក្យស្នើសុំចុះបញ្ជីណាដែលមិនមានលក្ខណៈត្រឹមត្រូវតាមច្បាប់នោះ ក្រសួងពាណិជកម្មមានសិទ្ធិបដិសេធមិនចុះបញ្ជីជូន ឬ លុបពាណិជសញ្ញា ឬ សេវាសញ្ញានោះចេញពីបញ្ជីវិញ ប្រសិនបើ :

- ពាណិជសញ្ញា ឬ សេវាសញ្ញា នោះអាចធ្វើអោយសាធារណជនភាន់ច្រឡំ
- ពាណិជសញ្ញា ឬ សេវាសញ្ញា នោះប្រើប្រាស់ក្នុងវិស័យសាធារណៈ
- ពាណិជសញ្ញា ឬ សេវាសញ្ញា នោះបង្ហាញចរិតលក្ខណៈរបស់ទំនិញឬសេវាសញ្ញាដែលពាក់ព័ន្ធ ដូចជា ប្រភេទ គុណភាព ឬ បរិមាណ ...
- ពាណិជសញ្ញា ឬ សេវាសញ្ញា នោះមានទ្រង់ទ្រាយជាទំនិញ ឬ សំបកវេចខ្ចប់របស់ទំនិញ
- ពាណិជសញ្ញា ឬ សេវាសញ្ញា នោះផ្ទុយនឹងសីលធម៌ សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទំលាប់ប្រពៃណី ឬ ច្បាប់ជាធរមាន ។
- ពាណិជសញ្ញា ឬ សេវាសញ្ញា ដែលលួចរបស់គេមកស្នើសុំចុះបញ្ជី ដោយម្ចាស់ដើមទំនិញមិនបានដឹង ។
- មានភាពជាន់គ្នានឹងពាណិជសញ្ញា ឬ សេវាសញ្ញាដែលបានចុះបញ្ជីត្រឹមត្រូវ និងស្របច្បាប់រួចហើយ ។

ប្រការ៧ : អ្នកដែលក្លែងបន្លំ និងមានចេតនា លើការចុះបញ្ជីពាណិជ្ជសញ្ញា ឬ សេវា សញ្ញ សំរាប់ប្រើប្រាស់ជាផលប្រយោជន៍ខុសច្បាប់នោះ នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ៨ : ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ តទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

* * *

៣_ទីស្ដីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣១៤/៩៧ ពម.ប្រក

ស្ដីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងពតិមាន
- យោងតាមសំណើរបស់នាយកដ្ឋានរដ្ឋបាល
- ពិនិត្យលើលក្ខណសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ១ : តែងតាំងមន្ត្រីរាជការចំនួន ០៤រូប ជាប្រធាន និងអនុប្រធានការិយាល័យ

នាយកដ្ឋានរដ្ឋបាល នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងពត៌មាន ដូចមានរាយនាមខាងក្រោមនេះ :

ក_ថ្នាក់ប្រធានការិយាល័យ :

១_លោក ខាំន់ ស៊ីណា ជាប្រធានការិយាល័យសរុប

២_លោក ឈឹម ឈឿន ជាប្រធានការិយាល័យតម្កល់ឯកសារ

ខ_ថ្នាក់អនុប្រធានការិយាល័យ :

១_លោក ជោ សុខុម ជាអនុប្រធានការិយាល័យសរុប

២_លោក ទីន រតនា ជាអនុប្រធានការិយាល័យរដ្ឋបាល

ប្រការ២ : ឯកឧត្តមអគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញកិច្ច និងអស់លោកក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣១៥/៩៧ ពម. ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងពត៌មាន

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងពតិមាន

-យោងតាមតម្រូវការចាំបាច់

-ពិនិត្យលើលក្ខណៈសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ១ : តែងតាំងមន្ត្រីរាជការចំនួន ០៣រូប ជាអនុប្រធានការិយាល័យនាយកដ្ឋានបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងពតិមានដូចមានរាយនាមខាងក្រោមនេះ:

១-លោក **យាន សុន្ធី** ជាអនុប្រធានការិយាល័យខេត្ត-ក្រុង

២-លោក **ចំនួ ណារិន** ជាអនុប្រធានការិយាល័យបណ្ដុះបណ្ដាល

៣-លោក **ឌី សុម៉ាឡា** ជាអនុប្រធានការិយាល័យកិច្ចការសង្គម

ប្រការ២ : ឯកឧត្តមអគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញកិច្ច និងអស់លោកក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

៤-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាសលេខ ៨៦២/អយក.ប្រក

ស្ដីពីការបើក អនុវិទ្យាល័យ ហ៊ុន សែន « ឈើទាល »

ស្ថិតក្នុងឃុំកោះក្រៅ ស្រុកជួនកែវ ខេត្តតាកែវ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញសារាចរណែនាំលេខ ៦៦ អរចទម ចុះថ្ងៃទី២ ខែ មេសា ឆ្នាំ ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតរបស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត តាកែវ លេខ ៣៦៦៦ អយក.ត មស. ចុះថ្ងៃទី២២ កញ្ញា ឆ្នាំ ១៩៩៦ ដោយមានចំណារបញ្ជូនរបស់អភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : **អនុវិទ្យាល័យ ហ៊ុន សែន « ឈើនាឈ »** ចាប់ពីឆ្នាំសិក្សា ១៩៩៧_៩៨ តទៅ ។

ប្រការ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀត តាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ៣ : នាយក នាយករងនៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច របស់នាយក នាយករង នៃអនុវិទ្យាល័យ ។

ប្រការ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និង

កីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

តា សាហាន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាសលេខ ៨៦៤/អយក.ប្រក

ស្តីពីការប្តូរឈ្មោះ អនុវិទ្យាល័យ ចាន់ថ្វាល ទៅជា

អនុវិទ្យាល័យ ប៊ុន រ៉ានី - ហ៊ុន សែន « ចាន់ថ្វាល »

ស្ថិតក្នុងឃុំក្រូចឆ្មារ ស្រុកខ្សាច់កណ្តាល ខេត្តកំពង់ស្ពឺ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត/០១៩៦/០១ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ

_ យោងលិខិតរបស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត កំពង់ស្ពឺ លេខ ១០៩ អយក. ចុះថ្ងៃទី១២ មីនា ឆ្នាំ ១៩៩៧ ដោយមានចំណារឯកភាពពី អភិបាល ខេត្តកំពង់ស្ពឺ

_ តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មធ្យមសិក្សា

សម្រេច

ប្រការ១ : អនុញ្ញាតអោយប្ដូរឈ្មោះ អនុវិទ្យាល័យ ចាន់ថ្លាល បច្ចុប្បន្នទៅជា អនុវិទ្យាល័យ ប៊ុនរ៉ានី _ ហ៊ុន សែន «ចាន់ថ្លាល» ចាប់ពីឆ្នាំសិក្សា ១៩៩៧_៩៨ តទៅ ។

ប្រការ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មធ្យមសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គា សាខន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាសលេខ ៤៦៥/អយក.ប្រក

ស្ដីពីការប្ដូរឈ្មោះ វិទ្យាល័យ កោះអណ្ដែត ទៅជា

វិទ្យាល័យ ហ៊ុន សែន « កោះអណ្ដែត »

ស្ថិតក្នុងស្រុកកោះអណ្ដែត ខេត្តតាកែវ

—

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

_ បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

– បានឃើញព្រះរាជក្រឹត្យ លេខ ជ្ជស.រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាល

– បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ ។

– យោងលិខិតរបស់មន្ទីរអប់រំ យុវជន និងកីឡា លេខ ១៣៩០ អយក.តមស ចុះថ្ងៃទី ១៤ ឧសភា ឆ្នាំ ១៩៩៧ ដោយមានចំណារបញ្ជូនរបស់អភិបាល ខេត្តតាកែវ

– តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ១ : អនុញ្ញាតអោយប្តូរឈ្មោះ វិទ្យាល័យ កោះអណ្តែត បច្ចុប្បន្នទៅជា **វិទ្យាល័យ ហ៊ុន សែន «កោះអណ្តែត»** ចាប់ពីឆ្នាំសិក្សា ១៩៩៧–៩៨ តទៅ ។

ប្រការ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ និងនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គា សាអាន

៥_ នីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧

ប្រកាសលេខ ២០៩/បទ

ស្តីពីថ្លៃសន្ទនាទូរស័ព្ទអន្តរជាតិ និង ថ្លៃសេវា

ស្ថាបនា_ផ្ទេរប្រព័ន្ធទូរគមនាគមន៍ក្នុងក្រុង

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃ ទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រមលេខ នស/រកម/០៤៩៦/២០ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

_បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី០៥ ខែ មីនា ឆ្នាំ ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រៃសណីយ៍ និង ទូរគមនាគមន៍

_បានឃើញសេចក្តីសំរេច លេខ ១៥៤ សសរ ចុះថ្ងៃទី១១ ខែ ធ្នូ ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីថានានុក្រមគ្រប់គ្រងតម្លៃ

_បានឃើញ កំណត់ហេតុអង្គប្រជុំនាថ្ងៃទី១០ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការកែប្រែតម្លៃស្ថាបនាទូរស័ព្ទ ។

សំរេច

ប្រការ១ : កំណត់តម្លៃសន្ទនាទូរស័ព្ទអន្តរជាតិ តម្លៃស្ថាបនាប្រព័ន្ធថ្មី និងផ្ទេរប្រព័ន្ធទូរគមនាគមន៍ ដូចមានក្នុងតារាងភ្ជាប់មកជាមួយនេះ។

ប្រការ២ : ការផ្គត់ផ្គង់សំភារៈបរិក្ខារ សំរាប់ការស្ថាបនាទូរស័ព្ទថ្មី ជាបន្ទុករ៉ាប់រងរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។ ដោយឡែក អតិថិជនអាចប្រើប្រាស់បរិធានទូរស័ព្ទចាស់ដដែល ក្នុងការផ្ទេរប្រព័ន្ធទូរគមនាគមន៍ ។

ប្រការ៣ : ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ៤ : ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកតាមតួនាទីភារកិច្ចអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ ឃុន

...

តារាងថ្លៃសន្ទនាទូរស័ព្ទអន្តរជាតិ ថ្លៃសេវាស្ថាបនា និង ផ្ទេរប្រព័ន្ធទូរគមនាគមន៍ក្នុងក្រុង ភ្ជាប់ប្រកាសលេខ ២០៩ បន

...

១_ថ្លៃសន្ទនាទូរស័ព្ទអន្តរជាតិ : ចាប់ពីសូន្យម៉ោងថ្ងៃទី១ ខែ មករា ឆ្នាំ ១៩៩៨ តទៅ :

១.១_តម្លៃធម្មតា សំរាប់ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ។

តំបន់	តម្លៃមុន	តម្លៃថ្មីក្នុង១នាទី
១.១.១. ប្រទេសឡាវ. វៀតណាម និង ថៃ	៣.២០ ដុល្លារ	២.៦០ ដុល្លារ
១.១.២. ប្រទេសអាស៊ីឯទៀត..................	៣.៤០ ដុល្លារ	២.៨០ ដុល្លារ
១.១.៣. ប្រទេសឯទៀត	៣.៨០ ដុល្លារ.........	៣.១០ ដុល្លារ

១.២ តម្លៃចុះ ២០% នៃតម្លៃធម្មតា សំរាប់ថ្ងៃសៅរ៍ និង ថ្ងៃអាទិត្យតាមតំបន់ខាងលើ :

គឺ ២.០៨ ដុល្លារ , ២.២៤ដុល្លារ , និង ២.៤៨ដុល្លារ ក្នុងមួយនាទី ។

<u>២_តម្លៃស្ថាបនាថ្មី និង ផ្ទេរប្រព័ន្ធទូរគមនាគមន៍ក្នុងក្រុង</u> :

ប្រភេទការងារ	ទូរស័ព្ទ	ទូរពុម្ព
២.១. ស្ថាបនានិងភ្ជាប់បណ្តាញថ្មី...........	២០០ដុល្លារ...........	៤០០ដុល្លារ
២.២ ផ្តត់ផ្តង់បរិធានទូរស័ព្ទនិងសំភារៈស្ថាបនា	៥០ដុល្លារ..........	គ្មាន
២.៣ ផ្ទេរទីកន្លែងក្នុងអាគារតែមួយ	១០ដុល្លារ	២០ដុល្លារ
២.៤ ផ្ទេរទីកន្លែង «អាស័យដ្ឋានថ្មី ».........	៨០ដុល្លារ	១៥០ដុល្លារ
២.៥ ផ្ទេរកម្មសិទ្ធិ «កាត់ឈ្មោះ »	៤០ដុល្លារ.........	៦០ដុល្លារ
២.៦ ប្តូរលេខទូរស័ព្ទ «ប្រព័ន្ធដូចគ្នាឬខុសគ្នា »	៤០ដុល្លារ........	គ្មាន
២.៧ ផ្តល់លេខទូរស័ព្ទប្រភេទ "HUNTING GROUP "	២០ដុល្លារ.....	គ្មាន

២.៨ បញ្ចូលលេខទូរស័ព្ទក្នុង "HUNTING GROUP" ២០ដុល្លារ..... គ្មាន

២.៩ ផ្អាកការប្រើប្រាស់បណ្តោះអាសន្ន (៣ខែ) ៥០%នៃតម្លៃជាវប្រចាំខែ ។

៣_ប្រាក់ធានាតំកល់ទុក :

៣.១ សេវាអន្តរជាតិ .... ២០០ដុល្លារ

៣.២ សេវាក្នុងប្រទេស.. ៦០ដុល្លារ

៤_ថ្លៃជួលជាវប្រចាំខែ :

៤.១ ទូរស័ព្ទ/ទូរសារ ....១៥ដុល្លារ

៤.២_ទូរពុម្ព «តេឡិច».. ៨០ដុល្លារ

៥_ថ្លៃផ្តល់វិក្កយបត្រលំអិត :

៥.១_ស្តីពីសន្ទនាទូរស័ព្ទក្នុងក្រុង .... ៣ដុល្លារមួយច្បាប់

សេចក្តីជូនដំណឹង លេខ ២១០ បន

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជំរាបសាធារណជនជ្រាបថា : ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ ១៩៩៨ នេះតទៅ ក្រសួងនឹងបញ្ចុះតម្លៃសន្ទនាទូរស័ព្ទអន្តរជាតិដូចតទៅ :

១_តម្លៃហៅទៅប្រទេសថៃ វៀតណាម និងឡាវ ចុះពី ៣.២០ដុល្លារ ក្នុង១នាទីមក ២.៦០ដុល្លារ ក្នុង១នាទី ។

២_តម្លៃហៅទៅប្រទេសអាស៊ីឯទៀត ចុះពី ៣.៤០ដុល្លារ ក្នុង១នាទីមក ២.៨០ដុល្លារ ក្នុង១នាទី ។

១_តម្លៃហៅទៅប្រទេសទាំងអស់ឯទៀត ចុះពី ៣.៨០ដុល្លារ ក្នុង១នាទីមក ៣.១០ដុល្លារ ក្នុង១នាទី ។

ចំណែកថ្ងៃសៅរ៍ និងអាទិត្យ គិតចុះថ្លៃ ២០% ដដែល ។

ទន្ទឹមនោះក្រសួងមានបញ្ចុះថ្លៃសេវាស្ថាបនាការ និង ផ្ទេរប្រព័ន្ធទូរគមនាគមន៍ក្នុងក្រុង ។

ធ្វើនៅថ្ងៃទី ១៥ ខែ ១២ ឆ្នាំ ១៩៩៧

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

សូ ឃុន

បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៤០០ ច្បាប់

តម្លៃ ២៧៥០ រៀល